ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សារបដិសេធទាំងស្រុងចំពោះការចុះផ្សាយព័ត៌មានបំផ្លើសខុសពីការពិត ដែលបានបង្ហោះចែកចាយនៅក្នុងប្រព័ន្ធទំនាក់ទំនងសង្គម *Facebook* កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ ២០២៤

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**




មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺអេដស៍សើស្បែក និងកាមរោគ សូមបដិសេធទាំងស្រុងចំពោះការចុះផ្សាយព័ត៌មានបំផ្លើសខុសពីការពិត ដែលបានបង្ហោះចែកចាយនៅក្នុងប្រព័ន្ធទំនាក់ទំនងសង្គម Facebook នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៤នេះ ដោយបានសរសេរមានខ្លឹមសារថា៖ "បើចង់ជាដាច់ពីជំងឺអេដស៍ LIV អាចជួយអ្នកបានព័ត៌មានលំអិត 0889988243 តេឡេក្រាម"។

ការចុះផ្សាយព័ត៌មានបំភ្លៃនេះបានធ្វើឱ្យសាធារណជន ជាពិសេសអ្នកជំងឺអេដស៍ផ្ទាល់យល់ច្រឡំ និងប៉ះពាល់ដល់ការព្យាបាលរបស់ក្រុមគ្រូពេទ្យយ៉ាងធ្ងន់ធ្ងរ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺអេដស៍សើស្បែក និងកាមរោគសូមអំពាវនាវដល់សាធារណជន ជាពិសេសអ្នកជំងឺអេដស៍ដែលកំពុងទទួលសេវាថែទាំព្យាបាលមេត្តាកុំជឿលើព័ត៌មានបំភ្លៃនេះ និងឈប់បន្តផ្សព្វផ្សាយ ឬចែកចាយតទៅទៀត។